Terre des Hommes Netherlands

# គន្លឹះសំរាប់ពុកម្តាយ និងអ្នកមើលថែកុមារ

## ត្រូវតែជជែកពីរឿងនេះ!

**សូមជជែកជាមួយកូនៗរបស់លោកអ្នកពីសុវត្ថិភាពរបស់ពួកគេនៅតាមប្រព័ន្ធអនឡាញ អោយដូចជាការជជែកពីសុវត្ថិភាពពួកគេនៅក្រៅប្រព័ន្ធអនឡាញផងដែរ។ លោកអ្នកបានបង្រៀនអោយកូនអស់លោកអ្នកពីរបៀបឆ្លងផ្លូវអោយមានសុវត្ថិភាព ដូចនេះ លោកអ្នកក៏ត្រូវបង្រៀនកូនៗរបស់លោកអ្នកពីសុវត្ថិភាពនៅតាមប្រព័ន្ធអនឡាញផងដែរ។**

# គន្លឹះក្នុងការជជែកជាមួយកុមារ

- ប្រើប្រាស់ព័ត៌មានថ្មីៗ កម្មវិធីទូរទស្សន៍ ឬ ប្រធានបទផ្សេងៗ ឧ. ការសួរពួកគេពីមិត្តភក្ករបស់ ពួកគេនៅសាលារៀនធ្លាប់ជួបបទពិសោធន៍ទាំងនេះដែរឬទេ?

- ត្រូវបង្រៀនកូនៗរបស់លោកអ្នកពីការកំណត់ និងគោរពព្រំដែននៅតាមប្រព័ន្ធអនឡាញ និង ពន្យល់ពួកគេអោយយល់ពីព្រំដែនកំណត់ដែលមនុស្សម្នាក់ៗមានព្រំដែនកំណត់ផ្សេងគ្នាៗផងដែរ និងលើកជាឧទាហរណ៏អោយពួកគេយល់ ថាពេលណាដែលដែនកំណត់ត្រូវបានគេបំពាន។

- ត្រូវលើកយកប្រធានបទណាដែលទាក់ទងនិងសកម្មភាពនប្រចាំថ្ងៃរបស់កូនរបស់អ្នក ដូចជាការទៅសាលារៀន ការញុំាអាហារ ដែលធ្វើអោយពួកគេមានអារម្មណ៍ថាងាយស្រួលក្នុងការជជែក

- ត្រូវពន្យល់ពួកគេអោយដឹងថា រូបភាពខ្លះអាចត្រូវយកទៅចែកចាយបន្ត ដោយគ្មានការអនុញ្ញាតពីម្ចាស់រូប និងអាចបង្កភាពឈឺចាប់ដល់ម្ចាស់រូប និងពន្យល់ពួកគេអោយប្រុងប្រយ័ត្នមុននិងគេចែករំលែករូបភាពរបស់ពួកគេទៅអោយអ្នកណាម្នាក់នៅតាមប្រព័ន្ធអនឡាញ។

បើលោកអ្នកត្រូវការព័ត៌មានបន្ថែម សូមចូលទៅកាន់ ហ្វេសប៊ុកផេក
**https://int.terredeshommes.nl/also-online**
ដើម្បីស្វែងយល់បន្ថែមក្នុងការជួយអោយកូនៗរបស់លោកអ្នកមានសុវត្ថិភាពនៅតាមប្រព័ន្ធអានឡាញ។